# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## របាយការណ៍

### កិច្ចប្រជុំបូកសរុបលទ្ធផលប្រចាំឆ្នាំ២០១៦ និងលើកទិសដៅផែនការ សកម្មភាពសម្រាប់ឆ្នាំ២០១៧ របស់ក្រុមការងារបច្ចេកទេសថ្នាក់ ជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសរួមភេទជាមួយ បុរស និងក្រុមបំប្លែងភេទ



**ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦**

**នៅសណ្ឋាគារ សោម៉ាទេវី ខេត្តសៀមរាប**

**រៀបចំដោយៈ អគ្គលេខាធិការដ្ឋាន នាយកដ្ឋានបង្ការថែទាំ និងគាំទ្រ**

## ១. សេចក្តីផ្តើម

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយក្រុមការងារលេខាធិកាដ្ឋានបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ ដោយមានការគាំទ្រថវិកាពីអង្គការMHSS និងMHC តាម រយៈគម្រោង Flagship បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលប្រចាំឆ្នាំ២០១៦ និង លើកទិសដៅផែនការសកម្មភាពសម្រាប់ឆ្នាំ ២០១៧ របស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ នៅព្រឹកថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ក្រោមការដឹកនាំរបស់ **ឯកឧត្តមវេជ្ជ. តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅសណ្ឋាគារសោម៉ាទេវី ខេត្តសៀមរាប ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង-ស្ថាប័ន អាជ្ញាធរមូលដ្ឋាន នគរបាល តំណាងអង្គការមិនមែនរដ្ឋាភិបាល ឪពុកម្តាយអាណាព្យាបាល និងក្រុមគោលដៅ។

## ២. គោលបំណងនៃកិច្ចប្រជុំ

ពិនិត្យមើលលទ្ធផលសម្រេចបាន ការលំបាក និងឧបសគ្គក្នុងការអនុវត្តន៍ការងារកន្លងមក និងលើកទិសដៅសម្រាប់អនុវត្តបន្ត។

បានអនុសាសន៍ល្អៗពីកិច្ចប្រជុំនេះ ដើម្បីរៀបចំផែនការសកម្មភាព សម្រាប់អនុវត្តឆ្នាំ ២០១៧។ របៀបវារៈនៃកិច្ចប្រជុំរួមមានដូចខាងក្រោម៖

១.ពិនិត្យមើលពីរបាយការណ៍សម្រេចបានរបស់ក្រុមការងារ ឆ្នាំ២០១៦

២.បទបង្ហាញពីគម្រោងlinkagesរបស់អង្គការFHI360 និងផែនការសកម្មភាពឆ្នាំ២០១៧ កម្មវិធីគាំពារផ្លូវច្បាប់ដល់ក្រុមប្រឈមមុខខ្ពស់

៣.បទបង្ហាញពីលទ្ធផលសកម្មភាពការផ្តល់សេវាពិនិត្យសុខភាពក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរសនិងក្រុមបំប្លែងភេទនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើរស្បែកនិងកាមរោគ។

៤.ការរៀបចំទិសដៅ និងយុទ្ធវិធីការងារសម្រាប់ក្រុមការងារបច្ចេកទេស ឆ្នាំ២០១៧។



## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រធានអង្គប្រជុំបានសម្របសម្រួលដំណើរការកិច្ចប្រជុំដូចតទៅៈ

**ប្រធានបទទី១.**

ចំណាប់អារម្មណ៍របស់លោក **ជួប សុខចំរើន** នាយកប្រតិបត្តិអង្គការខាណា បានជម្រាបជូនខាងក្រោមៈ

- កិច្ចប្រជុំបូកសរុបលទ្ធផលឆ្នាំ២០១៦ និងលើកទិសដៅយុទ្ធសាស្រ្តឆ្នាំ២០១៧ ជាអត្ថិភាពជាតិក្នុងការលុបបំបាត់ការឆ្លងថ្មីនាឆ្នាំ២០២៥ គឺក្រុមអាយុ១៥ ទៅ៤៩ឆ្នាំ ថយចុះមកនូវ០.៣%។
- ចំពោះការរកឃើញថ្មីៗសម្រាប់ក្រុមបំប្លែងភេទគឺ១១.៣%នៅខេត្តសៀមរាបនិង១១.៧% នៅខេត្តបន្ទាយមានជយ័។ ចំពោះការធ្វើតេស្តឈាម គឺបានត្រឹមតែ៥០%តែប៉ុណ្ណោះ និង៥០% ទៀតមិនទាន់ដឹងពីស្ថានភាពនៅឡើយ។
- សម្រាប់ក្រុមបំប្លែងភេទការធ្វើតេស្តឈាមមានកំរិតទាបនៅឡើយ ដោយមានភាពខ្លាចអោរក្នុងការមកទទួលសេវាសុខភាព ។ ដោយឡែកស្របពេលនឹងការផ្តល់ថវិកាមានការថយចុះរបស់ម្ចាស់មូលនិធិ ។

**ប្រធានបទទី២.**

ចំណាប់អារម្មណ៍របស់លោកស្រី **កុយ វិសាល** អភិបាលរងក្រុងសៀមរាបបានជម្រាបជូនខាងក្រោមៈ

- លោកស្រីបានរាយការណ៍ពីសកម្មភាពការងារ និងកិច្ចសហការជាមួយក្រុមការងារក្នុងឆ្នាំ ២០១៦ ដោយអាជ្ញាធរមូលដ្ឋាន សង្កាត់ ប៉ូលីសប៉ុស្ត៍ មានការសហការល្អរវាងអង្គការនៅសហគមន៍។ បានចូលរួមប្រជុំប្រចាំត្រីមាសជាមួយក្រុមបំប្លែងភេទ និងអង្គការ MHC គឺដំណើរការបាន២ដង ដោយមានការចូលរួមពីឳពុកម្តាយ និងសាច់ញាតិរបស់ក្រុមបំប្លែងភេទ ដើម្បីកាត់បន្ថយការរើសអើង និងមាក់ងាយដល់ក្រុមប្រឈម។ ជាមួយគ្នានោះ លោកស្រីបានស្នើរដល់ប្អូនៗដែលជាក្រុមគោលដៅ ចូលបង្ហាញមុខនៅមូលដ្ឋានដែលប្អូនរស់នៅ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងបានផ្តល់សេវា ដល់ប្អូនៗនៅពេលមានវគ្គបណ្តុះបណ្តាល សូមប្អូនៗចូលរួមឲ្យបានច្រើនព្រោះកន្លងមកក្រុមការងារកាកបាទក្រហមកម្ពុជា បានប្រកាសអោយប្អូនៗចុះឈ្មោះតែមិនមានអ្នកមកទេ។
- ក្រុមការងារបានបង្កើតហិបជួយសង្គ្រោះបានពីរវត្ត និងបានបន្តដាក់ហិបមួយទៀតនៅវត្តព្រះព្រហ្មរត្ន័។ ដោយឡែក លោកស្រីបានស្នើរឲ្យការប្រើប្រាស់ថវិកាក្នុងហិបនេះឲ្យមានភាពត្រឹមត្រូវ និងស្មោះត្រង់ប្រកបដោយកំលាភាព។
- លោកស្រីបានបន្តទៀតថា ចាប់ពីពេលនេះតទៅ សមត្ថកិច្ចមានការរិតបន្តឹង ចំពោះសណ្តាប់ធ្នាប់ និងសន្តិសុខសង្គម ដូចនេះ សំណូមពរដល់ក្មួយជាក្រុមMSM/TG ដែលចូលចិត្តដើរលេងយប់ សូមកាត់បន្ថយកុំដើរយប់ជ្រៅពេក។



<u>**ប្រធានបទទី៣.**</u>

លោក **ដោក បញ្ញា** នាយកប្រតិបត្តិអង្គការ MHSS បានបង្ហាញរបាយការណ៍វឌ្ឍនភាពរបស់ក្រុមការងារឆ្នាំ២០១៦៖

–សមាសភាពក្រុមការងារដែលបានអញ្ជើញចូលរួមប្រជុំប្រចាំឆ្នាំ២០១៦មាន៥៣រួមមាន៖

១.អាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍

២.មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ

៣.អន្តរក្រសួង

៤.អង្គការដៃគូ

៥.លេខាធិកាដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត អាជ្ញាធរមូលដ្ឋាន និងស្នងការខេត្ត

៦.ឪពុកម្ដាយអាណាព្យាបាល និងក្រុមគោលដៅ។

–បច្ចុប្បន្នភាពអង្គការដៃគូកំពង់អនុវត្តកម្មវិធីបង្ការ ក្នុងចំណោមក្រុមបុរសរួមភេទជាមួយ បុរស និងបំប្លែងភេទមានដូចជាៈ អង្គការKHANA ,PSK ,FHI360 ,UNAIDS និងAHF។ អង្គការដែលអនុវត្តផ្ទាល់មានអង្គការ MHSS, MHC, SIT, KHEMERA, CSSD, MEC, RHAC និងមានបណ្ដាញចតុមុខ បណ្ដាញCPN+។

–ក្រុមMSM/TGដែលទទួលបានការអប់រំខែតុលាឆ្នាំ២០១៥ដល់កញ្ញាឆ្នាំ២០១៦ រួមមាន៖

- ផែនការសំរាប់ក្រុមMSM=៣០៨៩១នាក់អប់រំបាន១៧៨៥៩នាក់ស្មើរនឹង៥៨%
- ផែនការសំរាប់ក្រុមTG=៤០៩៣នាក់ អប់រំបាន៣០៨៤នាក់ស្មើរនឹង៧៥%

–ក្រុមMSM/TGដែលទទួលបានតេស្តឈាមPDI+ក្នុងល្បាក់សេវាមេរោគអេដស៍ រួមមាន៖

- ក្រុមបុរសរួមភេទជាមួយបុរស៨៨០នាក់មានប្រតិកម្ម១៧នាក់ស្មើរ១.៩% និងបានទៅបញ្ជាក់តេស្ត១៣នាក់ លទ្ធផលវិជ្ជមាន១៣នាក់។
- ក្រុមស្រីស្រស់បុរស៤៧២នាក់មានប្រតិកម្ម ២៤នាក់ស្មើរ៥.១% និងបានទៅបញ្ជាក់តេស្ត១៩នាក់ លទ្ធផលវិជ្ជមាន១៩នាក់។

**–ឧបសគ្គ និងដំណោះស្រាយ៖**

- ពុំមានថវិកាសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការចូលរួមដល់ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធក្នុងកម្មវិធីបង្ការមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ តាមរយៈក្រសួងព័ត៌មាន។
- ពុំមានថវិកាសម្រាប់បង្កើតវេទិកាជាមួយសារព័ត៌មាន ដើម្បីកាត់បន្ថយការរើសអើងក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ។
- ពុំមានថវិកាសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលពិគ្រោះយោបល់ស្តីពីយេនឌ័រដល់ក្រុមការងារលេខាធិការដ្ឋាន និងក្រុមការងារថ្នាក់ជាតិ។
- ពុំមានថវិកាសម្រាប់រៀបចំផ្លាស់ប្តូរបទពិសោធន៍តាមរយៈកម្មសិក្សា ឬ ការចូលរួមកិច្ចប្រជុំនានាជាមួយអ្នកពាក់ព័ន្ធ។
- ពុំមានថវិកាសម្រាប់រៀបចំកិច្ចប្រជុំ ឬវេទិកាផ្លាស់ប្តូរយោបល់ជាមួយអង្គការពាក់ព័ន្ធគ្លីនិក និងមណ្ឌលសុខភាព ដើម្បីផ្លាស់ប្តូរយោបល់ និងព័ត៌មាន។



ប្រធានបទទី៤.

បទបង្ហាញស្តីពីគម្រោង Linkages របស់អង្គការ FHI360 និងផែនការសម្មភាព ឆ្នាំ២០១៧ នៃកម្មវិធីគាំពារផ្លូវច្បាប់ដល់ក្រុមប្រឈមមុខខ្ពស់ បង្ហាញដោយលោកវេជ្ជ.ទា ផូលី មាន ដូចតទៅ៖

–បញ្ហាសំខាន់ៗពាក់ពន្ធ័ទៅនឹងការអនុវត្តន៍ច្បាប់ និងគោលនយោបាយ រួមមាន៖

- ៩៤%នៃប៉ូលីសជឿថា ការចាប់ខ្លួន និងការឃុំខ្លួនក្រុមប្រឈមមុខខ្ពស់ គឺជាដំណោះស្រាយសមស្របក្នុងការកាត់បន្ថយការឆ្លងមេរោគអេដស៍ និងការប្រើប្រាស់គ្រឿងញៀន។
- ប៉ូលីសបានរាយការណ៍ថា ក្រុមគោលដៅត្រូវចាប់ខ្លួនដោយសារប្រើប្រាស់គ្រឿងញៀនមាន ៩៧% ។ ការលក់ភេទមាន៨៨% និងការប្រើប្រាស់ម្ទុលស៊ីរ៉ាំងរួមគ្នាមាន៥៥%។
- ១.៤%នៃក្រុមគោលដៅបានរាយការណ៍ថា មានការគំរាមកំហែងដោយប្រើពាក្យសំដី និងការប៉ះពាល់ដល់រាង្គកាយកាលពី៦ខែមុន។
- ១៣%នៃស្ត្រីបម្រើការនៅតាមគ្រឹះស្ថានកំសាន្តបានរាយការណ៍ថា មានការបង់ថវិកា ដើម្បីរួចផុតពីការចាប់ខ្លួន ឬការរំលោភបំពាន។
- ៥%នៃស្ត្រីបម្រើការកំសាន្តបានរាយការណ៍ថា មានការដោះដូរជាមួយការរួមភេទ ដើម្បីរួចផុតពីការចាប់ខ្លួន និងការរំលោភបំពាន។
- ជំនួយផ្នែកច្បាប់នៃកម្ពុជា(LAC) គឺជាអង្គការខ្មែរមិនមែនរដ្ឋាភិបាល ធ្វើការដើម្បីផ្តល់ដោយឥតគិតថ្លៃសេវាផ្នែកច្បាប់ប្រកបដោយគុណភាព ក្នុងការតស៊ូមតិ ដើម្បីជនក្រីក្ររបស់ប្រទេស កម្ពុជាទាំងនៅក្នុងករណីបទល្មើសព្រហ្មទណ្ឌ និងស៊ីវិល។

ប្រធានបទទី៥.

បទបង្ហាញលទ្ធផលសកម្មភាពនៃការផ្តល់សេវាពិនិត្យសុខភាព ក្នុងក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ បង្ហាញ ដោយលោកវេជ្ជ.**ឡាន វណ្ណសេង** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។ មានមាតិកាសំខាន់ៗដូចជា៖

- **ការស្វែងរកករណីឆ្លងមេរោគអេដស៍ថ្មីក្នុងចំណោមប្រជាជនងាយរងគ្រោះ (Oct 2015-Sept 2016)**

–ក្រុមប្រឈមដែលបានធ្វើការអប់រំ: ៦២០៤៣នាក់

–ក្រុមប្រឈមដែលបានធ្វើតេស្តរកមេរោគអេដស៍: ៣៦៦៣១នាក់

–តេស្តប្រតិកម្ម: ២៦៤នាក់

–ក្រុមប្រឈមដែលបានធ្វើតេស្តបញ្ជាក់វិជ្ជមាន: ២៣៤នាក់

–ក្រុមប្រឈមដែលបានចុះឈ្មោះទទួលការព្យាបាល: ២១៤នាក់

–ក្រុមប្រឈមដែលបានទទួលការព្យាបាល ART ៦៦នាក់

–LTFU: ១១

–ស្លាប់: ៣នាក់។

- **MSM: new case finding**

–ដែលបានធ្វើការអប់រំៈ ១៧៨៥៩នាក់

–ដែលបានធ្វើតេស្តរកមេរោគអេដស៍ៈ៩៨៦៧នាក់

–តេស្តប្រតិកម្មៈ ៥៧នាក់

–ដែលបានធ្វើតេស្តបញ្ជាក់វិជ្ជមានៈ ៥២នាក់

–ដែលបានចុះឈ្មោះទទួលការព្យាបាលៈ ៥២នាក់

–ដែលបានទទួលការព្យាបាលART ២០នាក់

–LTFU: ០

–ស្លាប់: ២

–TG: new case finding

–ដែលបានធ្វើការអប់រំៈ ៣០៨៤នាក់

–ដែលបានធ្វើតេស្តរកមេរោគអេដស៍ៈ៣២១២នាក់

–តេស្តប្រតិកម្មៈ ៩៥នាក់

–ដែលបានធ្វើតេស្តបញ្ជាក់វិជ្ជមានៈ ៩០នាក់

–ដែលបានចុះឈ្មោះទទួលការព្យាបាលៈ ៧១នាក់

–ដែលបានទទួលការព្យាបាលART ២៤នាក់

–LTFU: ៩

–ស្លាប់: ០ ។



ប្រធានបទទី៦.

កិច្ចពិភាក្សាជាក្រុម៤ក្រុមៈសំណួរៈតើយើងសម្រេចផែនការ២០១៦បានប៉ុន្មាន ?តើមានការលំបាក និងឧបសគ្គអ្វីខ្លះរារាំងដល់ការសម្រេចការងារនេះ ? តើយើងនឹងសម្រេចការងារអ្វីខ្លះសម្រាប់ឆ្នាំ២០១៧ ? តើត្រូវការគាំទ្រអ្វីខ្លះ ?

| ការអនុវត្តន៍ផែនការកន្លងមក | សកម្មភាព | គោលបំណង |
|---|---|---|
| ១ | ថ្នាក់ជាតិត្រូវមានការគាំទ្រនូវគម្រោងផែនការសកម្មភាព របស់ថ្នាក់មូលដ្ឋាន។ | ឲ្យមានការចូលរួមពីវិមជ្ឈការក្នុងការអនុវត្តន៍សកម្មភាព |
| | ចូលរួមដាំដើមឈើក្នុងទីសាធារណៈពីសំណាក់បុរសរួមភេទជាមួយបុរស និងក្រុម បំប្លែង ភេទ។ | ក្នុងកាបញ្ឈប់ការមាក់ងាយ និងការរើសអើងក្នុងក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ និងលើកទឹកចិត្តឲ្យពួកគាត់ចូលរួម ការងារសង្គម។ |
| ៣ | ជម្រុញមានការផ្សព្វផ្សាយឲ្យបានទូលំទូលាយពីថ្នាក់ មូលដ្ឋានជាពហុវិស័យរួមទាំង សារព័ត៌មានក្នុងការអប់រំមេរោគអេដស៍ និង ការរើសអើង | បញ្ឈប់ការមាក់ងាយ និងការអើសអើង និងជម្រុញលើកទឹកចិត្តដល់ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទឲ្យទៅទទួលសេវា |
| ៤ | ត្រូវការធនធានមនុស្សនិងបុគ្គលិកបន្ថែមក្នុងការផ្សព្វផ្សាយ | សហគមន៍មានការយល់ដឹងពីបញ្ហាអេដស៍ និងក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ |
| ៥ | ផ្សព្វផ្សាយ និងរៀបចំកិច្ចប្រជុំ២៥ខេត្ត ក្រុង | ផ្សព្វផ្សាយយុទ្ធសាស្រ្ត៩០-៩០-៩០ក្នុងឆ្នាំ ២០២០ |
| **ផែនការបន្ត** | **សកម្មភាព** | **គោលបំណង** |
| ១ | ថ្នាក់ជាតិត្រូវមានការគាំទ្រនូវគម្រោងផែនការសកម្មភាពរបស់ថ្នាក់មូលដ្ឋាន | ឲ្យមានការចូលរួមពីវិមជ្ឈការក្នុងការអនុវត្តន៍សកម្មភាព |
| ២ | ចូលរួមដាំដើមឈើក្នុងទីសាធារណៈពីសំណាក់ក្រុមបុរសរួមភេទជាមួយបុរសនិងក្រុមបំប្លែងភេទ | ក្នុងការបញ្ឈប់ការមាក់ងាយ និងការរើសអើង ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ និងលើកទឹកចិត្តឲ្យពួកគាត់ចូលរួមការងារសង្គម |
| ៣ | ជំរុញឲ្យមានការផ្សព្វផ្សាយបានទូលំទូលាយពីថ្នាក់មូលដ្ឋានជាពហុវិស័យរួមទាំងសារព័ត៌មានក្នុងការអប់រំ ស្តីពីមេរោគអេដស៍ និងការរើសអើង | បញ្ឈប់ការមាក់ងាយនិងការរើសអើងដើម្បីលើកទឹកចិត្តក្រុមបុរសរួមភេទជាមួយបុរស និង ក្រុមបំប្លែងភេទឲ្យទៅទទួលសេវា |
| ៤ | ត្រូវការធនធានមនុស្ស និងបុគ្គលិកបន្ថែមក្នុងការផ្សព្វផ្សាយ | សហគមន៍មានការយល់ដឹងពីបញ្ហាអេដស៍ និងតម្រូវការរបស់ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ |
| ៥ | មានផ្សព្វផ្សាយ និងរៀបចំកិច្ច ប្រជុំ២៥ខេត្តក្រុង | ផ្សព្វផ្សាយយុទ្ធសាស្រ្ត៩០៩០៩០ ក្នុងឆ្នាំ ២០២០ |

លទ្ធផលក្រុមទី១មាន: បង្ហាញដោយលោកផល សុផាត

លទ្ធផលក្រុមទី២ : បង្ហាញដោយលោកខែម វិចិត្រះ

១-តើមានសកម្មភាពអ្វីខ្លះដែលក្រុមការងារថ្នាក់ជាតិមិនបានអនុវត្តក្នុងឆ្នាំ២០១៦ ?

- រៀបចំកិច្ចប្រជុំ ឬវេទិកាផ្លាស់ប្តូរយោបល់ជាមួយអង្គការពាក់ព័ន្ធ គ្លីនិក និងមណ្ឌលសុខភាព ដើម្បីផ្លាស់ប្តូរយោបល់ និងព័ត៌មាន
- បង្កើនសមត្ថភាពដល់ក្រុមលេខាធិការដ្ឋាន
- រៀបចំផ្លាស់ប្តូរបទពិសោធន៍តាមរយៈកម្មសិក្សា និងកិច្ចប្រជុំនានាជាមួយអ្នកពាក់ព័ន្ធ

២-តើមានឧបសគ្គ ឬបញ្ហាសំខាន់ៗអ្វីខ្លះ ក្នុងការអនុវត្តន៍ផែនការសកម្មភាពឆ្នាំ២០១៦ ?

- ការចុះអភិបាលកិច្ចនៃការផ្តល់សេវាសុខភាពមិនទៀងទាត់ដោយសារខ្វះថវិកា
- រៀបចំកិច្ចប្រជុំសម្របសម្រួលថ្នាក់ក្រោមជាតិដល់អ្នកផ្តល់សេវាទាំងគ្រួសារ និងអាជ្ញាធរដែនដីមិនបានពេញលេញ(មិនគ្រប់គ្នា) ដោយសារជាប់រវល់ និងមិនហ៊ានប្រឈមមុខ។
- ការចងក្រងព័ត៌មាន និងឯកសារមិនបានគ្រប់ជ្រុងជ្រោយដោយសារពិបាកក្នុងការទំនាក់ទំនង។
- ការផ្លាស់ប្តូរបទពីសោធន៍តាមរយៈកម្មសិក្សា ឬ ការចូលរួមពិភាក្សាដោះស្រាយតាមកិច្ចប្រជុំនានាមិនបានទូលំទូលាយដោយសារខ្វះខាតថវិកា និងពេលវេលាគ្រប់គ្រាន់។
- ការផ្តល់ប្រាក់ឧបត្ថម្ភដល់អ្នកគាំទ្រសហគមន៍ (OW) នៅមានកំរិត
- បណ្តុះបណ្តាលចែករំលែកបទពិសោធន៍តាមរយៈត្រីមាសមិនគ្រប់ផែនការដោយមិនមានពេលវេលាគ្រប់គ្រាន់ និងខ្វះថវិកា។



៣-តើក្រុមការងារថ្នាក់ជាតិត្រូវធ្វើអ្វីបន្ថែមទៀតសម្រាប់អនុវត្តក្នុងឆ្នាំង២០១៧?  តើក្រុមការងារថ្នាក់ជាតិត្រូវការគាំទ្រផ្នែកអ្វីខ្លះ? សម្រាប់អនុវត្តផែនការសកម្មភាព?

- ការចុះអភិបាលកិច្ចអោយបានទៀងទាត់
- សំណូមពរបន្ថែមលើប្រាក់ឧបត្ថម្ភដល់អ្នកអប់រំសហគមន៍ឲ្យបានប្រសើរជាងមុន
- សុំឲ្យមានការគាំទ្រផ្នែកផ្លូវច្បាប់ដល់ MSM/ TG។

**លទ្ធផលក្រុមទី៣មាន:បង្ហាញដោយលោកសុខ សុឃីនះ**

**១-តើសកម្មភាពអ្វីខ្លះដែលក្រុមការងារថ្នាក់ជាតិមិនបានអនុវត្តក្នុងឆ្នាំ២០១៦?**

- មិនបានរៀបចំកិច្ចប្រជុំដល់ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនៅក្នុងកម្មវិធីបង្ការមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ តាមរយៈក្រសួង ព័ត៌មាន។
- មិនបានបង្កើតវេទិការជាមួយសារព័ត៌មាន ដើម្បីកាត់បន្ថយការរើសអើងក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ។
- មិនបានរៀបចំវគ្គបណ្តុះបណ្តាលពិគ្រោះយោលបល់ស្តីពី យេនឌ័រដល់ក្រុមការងារលេខាធិការដ្ឋាន និងក្រុមការងារថ្នាក់ជាតិ។
- មិនបានបង្កើនសមត្ថភាពដល់ក្រុមការងារលេខាធិការដ្ឋាន
- មិនបានរៀបចំផ្លាស់ប្តូរបទសោធន៍តាមរយៈកម្មសិក្សា ឬកិច្ចប្រជុំនានា
- មិនបានជម្រុញឲ្យស្ថាប័ននានាដែលធ្វើការងារជាមួយក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ។

**២-តើមានឧបសគ្គ ឬបញ្ហាសំខាន់ៗអ្វីខ្លះក្នុងការអនុវត្តន៍ផែនការសកម្មភាពឆ្នាំ២០១៦?**

- មិនសូវមានការចុះជួបផ្ទាល់ជាមួយក្រុមគោលដៅដែលមានផ្ទុកមេរោគអេដស៍ ដើម្បីកាត់បន្ថយការចំលងទៅអ្នកផ្សេង។
- មិនសូវបានចុះតាមដានឲ្យបានទៀងទាត់ជាមួយក្រុមគោលដៅ( NGO )
- ថ្នាក់ជាតិមិនសូវបានផ្សព្វផ្សាយពីផលប៉ះពាល់ពីមេរោគអេដស៍ទៅដល់ថ្នាក់ក្រោមជាតិ។

**៣-តើក្រុមការងារថ្នាក់ជាតិត្រូវធ្វើអ្វីបន្ថែមទៀតសម្រាមអនុវត្តក្នុងឆ្នាំ២០១៧?  តើក្រុមការងារថ្នាក់ជាតិត្រូវការគាំទ្រផ្នែកអ្វីខ្លះសម្រាមផែនការសកម្មភាព ?**

➢ *បន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់បញ្ចូលកម្មវិធីអេដស៍ទៅក្នុងគោលការណ៍ភូមិឃុំសុវត្ថិភាព*

- អាជ្ញាធរមូលដ្ឋាននឹងធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយទៅដល់ភូមិ ឃុំ ដោយមានផែនការច្បាស់លាស់ (២០១៧)។
- អាជ្ញាធរមូលដ្ឋានគួរតែសម្របសម្រួលធ្វើប័ណ្ណក្រក្រីដល់ក្រុមបុរសរួមភេទជាមួយបុរស និង ក្រុមបំប្លែងភេទដែលមានផ្ទុកមេរោគអេដស៍។
- ថ្នាក់ជាតិត្រូវដាក់ផែនការសម្រាប់ពង្រឹងសមត្ថភាពដល់ថ្នាក់ក្រោមជាតិអំពីកម្មវិធីអេដស៍

- ចុះធ្វើការប៉ាន់ប្រមាណពីការរើសអើងរបស់ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ នៅតាមសហគមន៍។
- ចុះសួរសុខទុក្ខ និងផ្តល់កញ្ចប់ស្បៀងអាហារូបត្ថម្ភដល់ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទនៅតាមសហគមន៍ដែលមានផ្ទុកមេរោគអេដស៍ និងស្ថានភាពលំបាក។
- ជម្រុញការផ្សព្វផ្សាយស្តីពីមេរោគអេដស៍នៅក្នុង Facebook page ( Mstyel and Srey Sros )។
- ពង្រឹងកិច្ចសហការរវាងអាជ្ញាធរដែនដី និង អង្គការសហគមន៍ ដោយដាក់ផែនការរួមគ្នាក្នុងការផ្សព្វផ្សាយកម្មវិធីអេដស៍តាមមូលដ្ឋាន។

**លទ្ធផលក្រុមទី៤ :បង្ហាញដោយលោកស្រី ប្រាក់ ស៊ីណាត:**

**១-សកម្មភាពដែលក្រុមការងារថ្នាក់ជាតិមិនបានអនុវត្តឆ្នាំ២០១៦?**

- មិនបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការចូលរួមដល់ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធក្នុងកម្មវិធីបង្ការមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ តាមរយៈក្រសួងព័ត៌មាន។
- បង្កើតវេទិកាជាមួយសារព័ត៌មាន ដើម្បីកាត់បន្ថយការរើសអើងលើក្រុមបុរសរួមភេទជាមួយ បុរស និងក្រុមបំប្លែងភេទ។
- រៀបចំវគ្គបណ្តុះបណ្តាលពិគ្រោះយោបល់ ស្តីពីយេនឌ័រដល់ក្រុមលេខាធិការដ្ឋាន និងក្រុមការងារថ្នាក់ជាតិ។
- បង្កើនសមត្ថភាពដល់ក្រុមលេខាធិការដ្ឋាន ដោយរៀបចំផ្លាស់ប្តូរបទពិសោធន៍តាមរយៈកម្មសិក្សា ឬការចូលរួមប្រជុំនានាជាមួយអ្នកពាក់ព័ន្ធ។
- ជម្រុញឲ្យស្ថាប័នធ្វើការងារជាមួយក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ ពង្រឹងការអនុវត្តន៍ការងារថ្នាក់សហគមន៍ (សមត្ថភាព ប្រាក់ឧបត្ថម្ភ គ្រឿងលើកទឹកចិត្ត)។



**២-ឧបសគ្គ ឬបញ្ហាសំខាន់ៗក្នុងការអនុវត្តន៍ផែនការសកម្មភាពឆ្នាំ២០១៦?**

- ខ្វះខាតថវិកាក្នុងការអនុវត្តន៍
- ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទផ្លាស់ប្តូរទីលំនៅ
- លំបាកក្នុងការប្រមូលផ្តុំ និងការចូលរួមពីក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ។

**៣- តើក្រុមការងារបច្ចេកទេសត្រូវធ្វើអ្វីបន្ថែមទៀតសម្រាប់អនុវត្តឆ្នាំ២០១៧?**

- រៀបចំបង្កើតឲ្យមានជនបង្គោលនៅតាមសង្កាត់ និងឃុំនីមួយៗ
- ចូលរួមប្រជុំគ.ក.ន.កនៅតាមសង្កាត់ជារៀងរាល់ខែពីតំណាងក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ។
- ផ្សព្វផ្សាយសេវាច្បាប់ និងសេវាពាក់ព័ន្ធសម្រាប់ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទនៅក្នុងខេត្តសហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ។
- ផ្សព្វផ្សាយគោលនយោបាយថ្មីអំពីភូមិ ឃុំ សុវត្ថិភាព និងបន្ថែមមួយចំណុចអំពីការបង្ការជំងឺអេដស៍។

បន្ទាប់ពីការបង្ហាញពីក្រុមនីមួយៗចប់ឯកឧត្តមវេជ្ជបណ្ឌិត **តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមការងារបេច្ចេកទេសថ្នាក់ជាតិបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ បានផ្តល់ឱកាសដល់គណៈអធិបតី និងតំណាងអាជ្ញាធរមូលដ្ឋាន អង្គការ ម្ចាស់ជំនួយមានមតិយោបល់ទូទៅសម្រាប់ការចូលរួមពេញមួយថ្ងៃនេះ។ អ្នកដែលចូលរួមជាមតិយោបល់ រួមមាន ស្នងការប៉ូលីសខេត្តសៀបរាប លោកស្រីវេជ្ជបណ្ឌិត នូ វណ្ណារី មកពីអង្គការAHF លោកវេជ្ជ បណ្ឌិត ទា ផូលី មកពីអង្គការ FHI360 លោក ជួប សុខចំរើន នាយកប្រត្តិបត្តិអង្គការខាណា លោកវេជ្ជបណ្ឌិត ឡាន វណ្ណសេង អនុប្រធានមជ្ឈមណ្ឌលជាតិ ប្រយុទ្ធជំងឺអេដស៍ សើស្បែក និងកាមរោគ លោកវេជ្ជបណ្ឌិត វ៉ឹង យ៉ាណាត ប្រធានក្រុមការងារបេច្ចេកទេសថ្នាក់ជាតិបុរសរួមភេទ ជាមួយបុរស និងក្រុមបំប្លែងភេទ និងចុងក្រោយមតិបូកសរុបបិទអង្គប្រជុំរបស់**ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** និងបន្តចូលរួមពិធីដាំកូនឈើអនុស្សាវរីយ៍។



## ៤. សំណូមពរ និងអនុសាសន៍

- ប៉ាន់ប្រមាណពីការមាក់ងាយ និងរើសអើងក្នុងចំណោមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ។
- បណ្តាញចតុមុខគួរមានតំណាងចូលរួមក្នុងក្រុមការងារនា ឆ្នាំ២០១៧
- ក្រុមការងារលេខាធិការដ្ឋានកោះប្រជុំ ដើម្បីពិនិត្យមើលផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សូមធ្វើការងារតាមប្រព័ន្ធ(ការចុះអភិបាលកិច្ច)ជួយបច្ចេកទេស និងធ្វើការរួមគ្នា
- សូមធ្វើការផ្សាភ្ជាប់គ្នារវាងកម្មវិធីជាតិ(NAA, NCHADS, Local Authority) ច្បាប់អេដស៍ ច្បាប់ផ្សេងៗទៀត។
- សូមរួមគ្នាដោះស្រាយទិដ្ឋភាពច្បាប់ក្នុងករណីមានបញ្ហាកើតឡើង និងនៅតែបន្តគាំទ្របន្តទៅមុខទៀត។
- ស្នើរអង្គការជំនួយផ្លូវច្បាប់ចូលរួមជាមួយក្រុមការងារលេខាធិការដ្ឋាន
- ស្នើរអង្គការដែលធ្វើការនៅតាមសហគមន៍បន្តសហការជាមួយអាជ្ញាធរដែនដី ក្រុមគោលដៅ ដើម្បីជួយការងារផ្សេងៗរបស់សង្គម។



## ៥. ផែនការបន្ទាប់

- រៀបចំកិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋាន ដើម្បីពិនិត្យមើលផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- បន្តវិះរកយុទ្ធវិធីចូលទៅដល់ក្រុមប្រឈមមុខខ្ពស់ ពិសេសក្រុមដែលលាក់មុខ ដែលមិនបានអប់រំ ដើម្បីឲ្យពួកគេទទួលបានព័ត៌មានអំពីសុខភាព និងតាមដានអ្នកដែលមានផ្ទុកមេរោគអេដស៍ ដើម្បីទទួលបានសេវា PreART/ART។
- បន្តកិច្ចសហការល្អជាមួយ អាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវា បុគ្គលិកអង្គការ និងអ្នកទទួលផល ដើម្បីធ្វើឲ្យប្រព័ន្ធនៃការបញ្ជូនទទួលបានជោគជ័យ។

ជាទីបញ្ចប់ ឯកឧត្តមប្រធាន បានអរគុណ និងបានកោតសរសើរចំពោះសមាជិកដែលបានចូលរួមប្រជុំនាពេលនេះ និងសូមឲ្យខិតខំបន្តសហការគ្នាល្អ និងជម្រុញការងារឆ្លើយតបការទប់ស្កាត់រីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីសម្រេចបាននូវគោលការណ៍៩០៩០៩០នាឆ្នាំ២០២០៕



រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦

| បានឃើញ និងឯកភាព<br>អគ្គលេខាធិការ | បានឃើញ និងពិនិត្យត្រឹមត្រូវ<br>ប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ | អ្នកធ្វើរបាយការណ៍ |
|---|---|---|
| 17-1-16 | | |